# I- ធីស្តីការគណៈរដ្ឋមន្ត្រី

## ១.អនុក្រឹត្យ

រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤

### អនុក្រឹត្យលេខ ៤៨ អនក្រ
### ស្តីពីការបែងចែកជំពូកចំណាយឥតគ្រោងទុក ឆ្នាំ ១៩៩៤

រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា

-បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័នព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំង រាជរដ្ឋាភិបាលកម្ពុជា

-បានឃើញច្បាប់ស្តីអំពីប្រពន្ធ័ហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រម លេខ ០១ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

-បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ នស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣

- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ ១៩៩៤

-យោងតាមសំណើរបស់ទេសរដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

### សំរេច

**មាត្រា ១ :** អនុញ្ញាតអោយធ្វើការផ្ទេរឥណទានពីជំពូក ៤១ ( ចំណាយមិនបានគ្រោងទុក ) នៃថវិការដ្ឋជូនទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុជំពូក៦២ ( ប្រាក់ឧបត្ថម្ភសំរាប់ដំណើរការអង្គការសាធារណៈរដ្ឋបាល ) ចំនួនទឹកប្រាក់ ៤២២.000.000រ00 ( បួនរយម្ភៃពីរលានរៀលគត់ ) សំរាប់ធ្វើការបែងចែកតាមបណ្តាខេត្តដូចមានខាងក្រោម :

- ខេត្តកំពត ១០០.០០០.០០០៛០០ ( មួយរយលានរៀលគត់ )
- ខេត្តកំពង់ធំ ១២៥.០០០.០០០៛០០ ( មួយរយម្ភៃប្រាំលានរៀលគត់ )
- ខេត្តកំពង់ឆ្នាំង ៧២.០០០.០០០៛០០ ( ចិតសិបប្រាំពីរលានរៀលគត់ )
- ខេត្តតាកែវ ៧០.០០០.០០០៛០០ ( ចិតសិបលានរៀលគត់ )

**មាត្រា ២ :** សហរដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ អភិបាលខេត្តដែលពាក់ពន្ធ័ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខានិងចុះហត្ថលេខា តទៅ ។

នាយករដ្ឋមន្ត្រីទី ១ — ព្រះហស្តលេខា និង ត្រា — **នរោត្តម រណឫទ្ធិ**

នាយករដ្ឋមន្ត្រីទី ២ — ហត្ថលេខា និង ត្រា — **ហ៊ុន សែន**

***

*រាជធានីភ្នំពេញ , ថ្ងៃទី ១៧ ខែ សីហា ឆ្នាំ ១៩៩៤*

## អនុក្រឹត្យលេខ ៤៩ អនក្រ
## ស្តីពីការផ្ទេរឥណទានចំណាយ

រាជរដ្ឋាភិបាលកម្ពុជា

- បានឃើញរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យរបស់ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម សីហនុវរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ០១ ខែវិច្ឆិកា ឆ្នាំ ១៩៩៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលកម្ពុជា
- បានឃើញច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០១ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញច្បាប់ហិរញ្ញវត្ថុសំរាប់ឆ្នាំ១៩៩៤ ដែលប្រកាសអោយប្រើដោយព្រះរាជក្រមលេខ ០២ ន.ស ចុះថ្ងៃទី ២៨ ខែ ធ្នូ ឆ្នាំ ១៩៩៣
- បានឃើញអនុក្រឹត្យលេខ ០១ អនក្រ ចុះថ្ងៃទី ០៥ ខែ មករា ឆ្នាំ ១៩៩៤ ស្តីពីការបែងចែកឥណទានតាមជំពូកនៃច្បាប់ ហិរញ្ញវត្ថុសំរាប់ ឆ្នាំ ១៩៩៤
- តាមសំណើរបស់ទេសរដ្ឋមន្ត្រី និង ជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ